# អភិបាលរងខេត្តតំណាងឯកឧត្តមអភិបាលខេត្ត និង តំណាងមជ្ឈមណ្ឌលជាតិអញ្ជើញចូលរួមចែកមុងជ្រលក់ថ្នាំជូនប្រជាពលរដ្ឋចំនួន ១២៨៥ នាក់ នៅខេត្តកំពង់ឆ្នាំង

ដើម្បីសំរេចបាននូវយុទ្ធសាស្រ្តជាតិលុបបាត់ជំងឺគ្រុនចាញ់ក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១១-២០២៥របស់រាជរដ្ឋាភិបាល កម្ពុជាដែលមានក្រសួងសុខាភិបាលជាសេនាធិការរបស់រាជរដ្ឋាភិបាលតាមរយៈមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានយកចិត្តទុកដាក់រិះរកគ្រប់មធ្យោបាយនិងវិធីសាស្រ្តផ្សេងៗដើម្បីបង្ការការពារនិងទប់ស្កាត់ការរាតត្បាតនៃជំងឺគ្រុនចាញ់ ដោយ បានធ្វើការផ្សព្វផ្សាយអប់រំសុខភាព ជូនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុង តំបន់ដែលប្រឈម និងងាយរងគ្រោះដោយសារជំងឺគ្រុនចាញ់ឱ្យចេះធ្វើ ការបង្ការការពារ និង ទប់ស្កាត់ជាមុននិងស្វែងរកការធ្វើរោគវិនិច្ឆ័យបានត្រឹមត្រូវដើម្បីការពារករណីធ្ងន់ធ្ងរដែលអាចបណ្តោលឱ្យស្លាប់បាត់បង់ជីវិត។

រាជរដ្ឋាភិបាលកម្ពុជារួមសហការជាមួយមូលនិធីសកលបានធ្វើការចែកមុងជ្រលក់ថ្នាំជូនប្រជាជន ដែលងាយរងគ្រោះក្នុង តំបន់រាតត្បាតនៃជំងឺគ្រុនចាញ់ដោយឥតគិតថ្លៃ ពិធីចែកមុងជ្រលក់ថ្នាំត្រូវបានធ្វើនៅក្នុងខេត្តចំនួន ២០ ដែលជាតំបន់ប្រឈមនឹងជំងឺគ្រុនចាញ់ដោយមានការចូលរួមត្រួតពិនិត្យ ដោយមន្រ្តីនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ថ្នាក់ដឹកនាំនៃមន្ទីរសុខាភិបាលខេត្ត អាជ្ញាធរដែនដី ព្រមទាំងមន្រ្តីនៃស្ថាប័នពាក់ព័ន្ធ ក្នុងមូលដ្ឋានផងដែរ។ ដោយឡែកនៅខេត្ត

កំពង់ឆ្នាំង យុទ្ធនាការចែកមុងជ្រលក់ថ្នាំ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២១-២៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងនោះចំនួនមុងសរុបដែលត្រូវធ្វើការបែងចែកមានចំនួន៦៥៧៥០មុងជូន ដល់ប្រជាពលរដ្ឋចំនួន ៥២៨៧១ នាក់ត្រូវជា ១១៣៩៦ គ្រួសារ ទៅតាម កម្មវិធីនិងទីកន្លែងដែលបានកំណត់។ ពិធីចែកមុងជានិមិត្ត រូបបាន ប្រព្រឹត្តកាលពីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ នៅក្នុងឃុំ ត្រញ៉ុងម្ទេស (ក្នុងវត្តត្រញ៉ុងម្ទេស) ស្រុកសាមគ្គីមានជ័យដែលមាន ប្រជាពលរដ្ឋមកពីភូមិ ចំនួន ០៦ រួមមាន ៖ ភូមិក្បោកពង់ **ត្រពាំងព្រីង ដំណាក់ព្រីង ត្រពាំងម្ទេស ច្រកសង្កែ និងភូមិព្រៃញាម**។ ពិធីនេះបានប្រព្រឹត្តទៅដោយមានការចូលរួមពីសំណាក់:

1- ឯកឧត្តម **សៀត គមលៀង** អភិបាលខេត្តរងខេត្តកំពង់ឆ្នាំង និងជាប្រធានក្រុមការងារពិសេសលុបបំបាត់ជំងឺ គ្រុនចាញ់ខេត្ត

2-លោកវេជ្ជបណ្ឌិត **ហេង ពិសាល** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ បាណកសាស្រ្ត និង ប៉ារ៉ាស៊ីតសាស្រ្ត

3-លោកវេជ្ជបណ្ឌិត **ប្រាក់ វ៉ុន** ធានមន្ទីរសុខាភិបាលខេត្តកំពង់ឆ្នាំង

4- លោក **ឱម សំអឿន** អភិបាលរងស្រុកសាមគ្គីមានជ័យ-ខេត្តកំពង់ឆ្នាំង

ព្រមទាំងលោក-លោកស្រីដែលជាមន្រ្តីមកពីមជ្ឈមណ្ឌលជាតិ និង លោក -លោកស្រីដែលជាមន្រ្តីនៃមន្ទីរសុខាភិបាលខេត្ត កំពង់ឆ្នាំង លោក-លោកស្រី ដែលតំណាងអោយអាជ្ញាធរមូលដ្ឋាន ព្រះសង្ឃ និង

ប្រជាពលរដ្ឋដែលបាន អញ្ជើញមកចូលរួមក្នុងពីធី នាពេលព្រឹកនេះមានចំនួនសរុប ១២៨៥ នាក់ផងដែរ។

ក្នុងឱកាសនោះលោក វេជ្ជ. **ហេង ពិសាល** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ បាណកសាស្ត្រ និងប៉ារ៉ាស៊ីត សាស្ត្របានជំរាប ជូនទៅកាន់អ្នកចូលរួមទាំអស់ថាការចែកជូននូវមុងជ្រលក់ថ្នាំ និងការចុះបញ្ជីរ គ្រួសារដើម្បីទទួលមុងជ្រលក់ថ្នាំត្រូវ បានធ្វើដោយឥតគិតថ្លៃ ។ ដើម្បីឱ្យសាធារណៈជនកាន់តែបានដឹងច្បាស់ពីគោលការណ៍នៃការចែកមុង ជ្រលក់ថ្នាំនេះ និងដើម្បីជៀសវាងនូវបាតុភាពអសកម្មផ្សេងៗក្រុមការងារ ទទួលបន្ទុកខេត្តកំពង់ឆ្នាំងដែលដឹកនាំដោយលោកវេជ្ជ. **ហេង ពិសាល** បានថតជាសំលេងនូវគោលការណ៍ចែកមុងជ្រលក់ថ្នាំដោយឥតគិតថ្លៃ ជាខ្សែអាត់ និងស៊ីឌីដើម្បីចាក់ផ្សាយជូនសាធារណៈជនជ្រាបជាព័ត៌មាន។ លោកអនុប្រធានមជ្ឈមណ្ឌលជាតិក៏បានមានប្រសាសន៍បញ្ជាក់ ជូន ប្រជាពលរដ្ឋក៏ដូចជាអាជ្ញាធរដែនដីទាំងអស់ថាប្រជាពលរដ្ឋម្នាក់ៗនឹងត្រូវ បានទទួលមុងជ្រលក់ថ្នាំមួយនឹងមុងអង្រឹងជ្រលក់ថ្នាំមួយក្នុងមួយគ្រួសារ ទៀតផងដែរ។ ក៏ប៉ុន្តែចំពោះប្រជាពលរដ្ឋណាដែលធ្លាប់បាន ទទួលមុងជ្រលក់ថ្នាំ ម្តងរួចហើយក្នុងកំឡុងពេលក្រោម៣ឆ្នាំមុននឹងមិនត្រូវបានផ្តល់ជូននូវមុងជ្រលក់ថ្នាំទៀតទេ។មុងជ្រលក់ថ្នាំដែល បានចែកជូនប្រជាពលរដ្ឋដោយ ឥតគិត ថ្លៃនាពេលនេះជាអំណោយដ៏ថ្លៃថ្លារបស់រាជរដ្ឋាភិបាលកម្ពុជាក្រោម ការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។